# របាយការណ៍ប្រចាំខែ មីនា ឆ្នាំ ២០១៥ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តឧត្តរមានជ័យ

## ១. សេចក្តីផ្តើម

ខេត្តឧត្តរមានជ័យស្ថិតនៅទិសឧត្តរនៃព្រះរាជាណាចក្រកម្ពុជា មានចម្ងាយប្រមាណ ៤៤១ គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ មានផ្ទៃដីសរុបចំនួន ៦.៦៣១,៧២ គីឡូម៉ែត្រក្រឡា។ ខេត្តនេះមានព្រំប្រទល់ខាងកើតជាប់នឹងខេត្តព្រះវិហារ ខាងលិចជាប់នឹង ខេត្តបន្ទាយមានជ័យ ខាងត្បូងជាប់នឹងខេត្តសៀមរាប និងខាងជើងប្រវែង ២២៥ គីឡូម៉ែត្រជាប់នឹងខេត្តស៊ីសាកេត ខេត្តបុរីរ៉ាំ និងខេត្តសុរិន្ទ្រ ប្រទេសថៃ និងមានស្រុកចំនួន ០៤ និងក្រុង ១ គឺស្រុកអន្លង់វែង ស្រុកត្រពាំងប្រាសាទ ស្រុកចុងកាល់ ស្រុកបន្ទាយអំពិល និងក្រុងសំរោង។

## ២. ស្ថានភាពរបស់មន្ទីរ

### ២.១ ការងាររដ្ឋបាល និងបុគ្គលិក

មន្ទីរអភិវឌ្ឍន៍ជនបទខេត្តឧត្តរមានជ័យ ដឹកនាំដោយប្រធានមន្ទីរ ០១ រូប និងអមដោយអនុប្រធានមន្ទីរចំនួន ០២ រូប រួមមាន បុគ្គលិកសរុបចំនួន ៣៣ នាក់ ក្នុងនោះនៅកម្រិតរដ្ឋបាលថ្នាក់មន្ទីរមានការិយាល័យជំនាញចំនួន០៨ និងថ្នាក់ស្រុក ០៥។

### ២.២ កិច្ចប្រជុំផ្សេងៗ និងទំនាក់ទំនងសាធារណៈ

- ថ្ងៃទី២៦ ខែកុម្ភៈ មន្ត្រីការិយាល័យបានចូលរួមប្រជុំផ្សព្វផ្សាយច្បាប់ ស្តីពីព្រៃឈើ និងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន
- ថ្ងៃទី០២ ខែមីនា មន្ត្រីការិយាល័យបានចូលរួមពិធីប្រកាសតែងតាំងមុខតំណែងប្រធានមន្ទីរសុខាភិបាលនៅសាលប្រជុំសាលាខេត្តឧត្តរមានជ័យ
- ថ្ងៃទី០៣-០៤ ខែមីនា មន្ត្រីការិយាល័យបាន ចូលរួមសន្និសីទជាតិអាហារូបត្ថម្ភ នៅសណ្ឋាគារអាំងទ័រកង់ទីណង់កាល់ រាជធានីភ្នំពេញ
- ថ្ងៃទី០៥ ខែមីនា មន្ត្រីការិយាល័យបានចូលរួមកិច្ចប្រជុំពិភាក្សាលើគម្រោងស្តារឡើងវិញផ្លូវជាតិលេខ ៥៨ (ប៉ោយប៉ែត ក្រុងសំរោង) នៅសាលប្រជុំសាលាខេត្តឧត្តរមានជ័យ
- ថ្ងៃទី០៦ ខែមីនា លោកប្រធានមន្ទីរបានចូលរួមពិធីទិវាវប្បធម៌ជាតិ ០៣ មីនា លើកទី **១៧** ឆ្នាំ២០១៥ នៅសាលប្រជុំសាលាខេត្តឧត្តរមានជ័យ
- ថ្ងៃទី០៦ ខែមីនា មន្ត្រីការិយាល័យបានចូលរួមប្រារព្ធខួបលើកទី ១០៤ ទិវាអន្តរជាតិនារី ០៨ មីនា ឆ្នាំ ២០១៥ ក្រោមអធិបតីភាព ឯកឧត្តម **ស ថាវី** អភិបាលខេត្ត និងលោកជំទាវ នៅសាលប្រជុំធំសាលាខេត្តឧត្តរមានជ័យ
- ថ្ងៃទី០៦ ខែមីនា ថ្នាក់ដឹកនាំមន្ទីរចូលរួមពិធីប្រកាសចូលកាន់តំណែងអភិបាលស្រុកអន្លង់វែង នៅសាលាស្រុកអន្លង់វែង

- ថ្ងៃទី០៧ ខែមីនា ថ្នាក់ដឹកនាំមន្ទីរបានចូលរួមពិធីសម្ពោធផ្លូវក្នុងភូមិសាស្ត្រស្រុកត្រពាំងប្រាសាទ ក្រោមអធិបតីភាពឯកឧត្តម **ស ថាវី** អភិបាលខេត្ត នៅទីស្នាក់ការក្រុមហ៊ុន Oddor Meanchey Sugar (ODMS) co,Ltd ភូមិឈើទាលជ្រុំ ឃុំអូរស្វាយ
- ថ្ងៃទី០៩ ខែមីនា លោកប្រធានមន្ទីរ និងថ្នាក់ដឹកនាំមន្ទីរ ចូលរួមពិធីប្រកាសតែងតាំងនាយករដ្ឋបាលសាលាខេត្ត នៅសាលប្រជុំសាលាខេត្តឧត្តរមានជ័យ
- ថ្ងៃទី១២ ខែមីនា លោកប្រធានមន្ទីរ ចូលរួមប្រជុំសាមញ្ញលើកទី១០ របស់ក្រុមប្រឹក្សាខេត្ត អាណត្តិទី ២ ក្រោមអធិបតីភាព ឯកឧត្តម **យឹម ធិន** ប្រធានក្រុមប្រឹក្សាខេត្តនៅសាលប្រជុំធំសាលាខេត្តឧត្តរមានជ័យ
- ថ្ងៃទី១២ ខែមីនា ថ្នាក់ដឹកនាំមន្ទីរ បានចូលរួមពិធីបើកការប្រកួតកីឡាមហាជនជ្រើសរើសជើងឯកថ្នាក់ខេត្ត ឆ្នាំសិក្សា២០១៤-២០១៥ នៅពហុកីឡាដ្ឋាន ខេត្តឧត្តរមានជ័យ
- ថ្ងៃទី១៣ ខែមីនា មន្ត្រីការិយាល័យ បានចូលរួមប្រជុំ Pro TWGH និងគណកម្មការហិរញ្ញប្បទាន នៅមន្ទីរសុខាភិបាលខេត្តឧត្តរមានជ័យ
- ថ្ងៃទី១៤ ខែមីនា មន្ត្រីការិយាល័យ បានចូលរួមពិធីបិទការប្រកួតកីឡាមហាជនជ្រើសរើសជើងឯកថ្នាក់ខេត្ត ឆ្នាំសិក្សា២០១៤-២០១៥ នៅពហុកីឡាដ្ឋាន ខេត្តឧត្តរមានជ័យ
- ថ្ងៃទី១៧ ខែមីនា លោកប្រធានមន្ទីរ និងមន្ត្រីការិយាល័យបានចូលរួមពិធីចែកប័ណ្ណកម្មសិទ្ធិ និងចែកអំណោយជូនប្រជាពលរដ្ឋក្រោមអធិបតីភាព ឯកឧត្តម **ស ថាវី** អភិបាលខេត្ត នៅច្រកជប់គតី ស្រុកបន្ទាយអំពិល
- ថ្ងៃទី១៩ ខែមីនា ថ្នាក់ដឹកនាំមន្ទីរ បានចូលរួមពិធីសម្ពោធពិពណ៌អបអរសាទរ ពិធីបុណ្យដាលានបញ្ចប់រដូវច្រូតកាត់លើកទី០១ ឆ្នាំ២០១៥ ក្រោមអធិបតីភាពភាព ឯកឧត្តម **ស ថាវី** អភិបាលខេត្ត នៅសណ្ឋាគារ និងកាស៊ីណូ សាង៉ាំ វីសត
- ថ្ងៃទី១៩ ខែមីនា មន្ត្រីការិយាល័យ បានចូលរួមប្រជុំស្ដីពីបញ្ហាមន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកអណ្ដែតសម្រាប់ឆ្នាំ ២០១៥ នៅទីស្ដីការក្រសួងអភិវឌ្ឍន៍ជនបទ និង
- ថ្ងៃទី១៩ ខែមីនា មន្ត្រីការិយាល័យ បានចូលរួមប្រជុំផ្សព្វផ្សាយសេចក្ដីសម្រេច ស្ដីពីការបង្កើតក្រុមការងារ ដើម្បីគ្រប់គ្រង និងជំរុញក្នុងការផ្ដល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋខេត្តឧត្តរមានជ័យ ក្រោមអធិបតីភាព ឯកឧត្តម **ស ថាវី** អភិបាលនៃគណៈអភិបាលខេត្ត ។

## ៣. លទ្ធផលសម្រេចបានតាមវិស័យ

### ៣.១ ការងារផ្លូវជនបទ

ចុះក្រាលក្រួសក្រហមនៅស្រុកអន្លង់វែង ប្រវែងសរុប ៣ ៦៣២ ម៉ែត្រ នៅស្រុកចុងកាល់ ប្រវែងសរុប ៤០០ ម៉ែត្រ នៅស្រុកបន្ទាយអំពិល ប្រវែងសរុប ២ ៣៩៥ ម៉ែត្រ និងនៅក្រុងសំរោង ប្រវែងសរុប ២ ៩៨០

ម៉ែត្រ របស់គម្រោងឧត្ថម្ភស្បៀងបន្ទាន់ ។

**៣.២ ការិយាល័យថែទាំសុខភាពជនបទ**

- ថ្ងៃទី២៧ ខែកុម្ភៈ មន្ត្រីការិយាល័យ បានចូលរួមសិក្ខាសាលាមួយស្តីពី សិក្ខាសាលាបញ្ចប់កម្មវិធីផ្នែកសុខភាពអាហារូបត្ថម្ភ បំនិនជីវិត និងអនាម័យ អនុវត្តតាមរយៈអង្គការ Plan និងអង្គការដៃគូរ ក្រោមអធិបតីភាពឯកឧត្តម **វង្ស សណ្ដាប់** អនុរដ្ឋលេខាធិកា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជានាយកគម្រោងឧបត្ថម្ភស្បៀងបន្ទាន់-ហិរញ្ញប្បទានបន្ថែម (EFAP-AF) ថ្នាក់ជាតិនៅសណ្ឋាគារ ខេមរាអង្គ ខេត្តសៀមរាប និង
- ថ្ងៃទី២០-២៨ ខែកុម្ភៈ មន្ត្រីការិយាល័យ ចុះពិនិត្យ និងផ្ទៀងផ្ទាត់ឡើងវិញទៅលើភូមិដែលបានបញ្ឈប់ការបន្ទោបង់ពាសវាលពាសកាល ១០០%ចំនួន ០៩ ភូមិ ស្ថិតក្នុងឃុំក្រសាំង ស្រុកចុងកាល់ រួមមានភូមិគោកស្អាន គោកសម្រេច គោកធំ គោល ឈូក ចេក្ស រលំវែង បន្ទាត់បោះ និងភូមិខ្នា។ សកម្មភាពនេះ មានក្រុមការងារចុះត្រួតពិនិត្យ និងវាយតម្លៃ ដែលមានសមាសភាពមកពី PDRD អាជ្ញាធរឃុំ ថ្នាក់ភូមិ និងប្រជាពលរដ្ឋចូលរួមសរុបចំនួន ៤០៥ នាក់ ស្ត្រី ចំនួន ២៦៣ នាក់ ។

**៣.៣ ការិយាល័យផ្គត់ផ្គង់ទឹកស្អាត**

- ថ្ងៃទី១៧ ខែមីនា មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត បានបើកកិច្ចប្រជុំថ្នាក់ខេត្ត ស្តីពីការត្រៀមរៀបចំកសាងផែនការសកម្មភាពសម្រាប់ការងារផ្គត់ផ្គង់ទឹក និងអនាម័យជនបទខេត្ត ២០១៤-២០១៨ សម្របសម្រួលដោយលោក ប្រិច វ៉ាមី អនុប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត
- ថ្ងៃទី១៧-២០ ខែមីនា ឆ្នាំ២០១៥ មន្ត្រីការិយាល័យ សហការជាមួយគណៈកម្មការហិញ្ញប្បទានមន្ទីរសុខាភិបាលខេត្ត ចុះត្រួតពិនិត្យ និងសម្ភាសន៍អ្នកជម្ងឺនៅមន្ទីរពេទ្យបង្អែកស្រុកអន្លង់វែង បាន ១៣ ភូមិ ០៤ ឃុំ ស្មើនឹង ៣២ នាក់ និងនៅស្រុកត្រពាំងប្រាសាទ បាន ០៣ ភូមិ ០២ ឃុំ ស្មើនឹង ១២ នាក់ គាំទ្រហិរញ្ញប្បទានដោយអង្គការមូលនិធិសមធម៌ (CHC) និង
- ថ្ងៃទី១៩ ខែមីនា មន្ត្រីការិយាល័យបានចូលរួមប្រជុំក្រុមការងារបច្ចេកទេសចម្រុះវិស័យ នៅមន្ទីរអប់រំ យុវជន និងកីឡា ។

**៣.៤ ការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ** ÷ ចុះស្រង់ទិន្នន័យផ្សារជនបទ នៅស្រុកចុងកាល់។

**៣.៥ ការិយាល័យការិយាល័យក្រុង -ស្រុក**

- ចូលរួមកិច្ចប្រជុំ គ.ក.ស.ក. ប្រចាំខែកុម្ភៈ នៅសាលាក្រុងសំរោង
- ចូលរួមសិក្ខាសាលាតម្រង់ទិស ស្តីពីកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចតំបន់ក្រវ៉ាត់បៃតង រៀបចំដោយអង្គការ GIZ នៅសាលាក្រុងសំរោង **និង**
- ចូលរួមប្រជុំផ្សព្វផ្សាយ ស្តីពីការប្រើប្រាស់ទឹកស្អាត និងអនាម័យនៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត។

### ៤. ទិសដៅការងារបន្ត

- ចុះធ្វើបច្ចុប្បន្នភាព និងស្រង់ទិន្នន័យផ្លូវថ្មី ក្នុងស្រុកទាំង ៤ និងក្រុង ១ ស្ថិតក្នុងខេត្តឧត្តរមានជ័យ
- ចុះតាមដានបច្ចេកទេសផ្លូវក្រាលគ្រួសក្រហម របស់គម្រោងឧត្ថម្ភស្បៀងបន្ទាន់
- ប្រជុំជ្រើសរើសទីតាំងអណ្តូងស្នប់អាហ្វ្រីដេវចំនួន ៤៥អណ្តូង និងស្រះសហគមន៍ ០១កន្លែង (MRD)
- សាងសង់អណ្តូងស្នប់អាហ្វ្រីដេវ ២១ អណ្តូង នៅស្រុកត្រពាំងប្រាសាទ ស្រុកចុងកាល់ និងស្រុកបន្ទាយអំពិល
- ជួសជុលអណ្តូងស្នប់អាហ្វ្រីដេវ ១៣ អណ្តូង នៅក្រុងសំរោង និងស្រុកបន្ទាយអំពិល
- ជួសជុលអណ្តូងស្នប់លេខ៦ ចំនួន ១១ អណ្តូង នៅក្រុងសំរោង
- សាងសង់ស្រះសហគមន៍ ០១ កន្លែង នៅស្រុកបន្ទាយអំពិល
- រៀបចំផែនការសម្រាប់ត្រីមាសទី ១ និងទី ២ ឆ្នាំ២០១៥ និង
- ចុះស្រង់ទិន្នន័យធនាគារស្រូវ គោ ក្នុងស្រុកចុងកាល់ ។